# ព្រះរាជក្រឹត្យ នស/រកត/០៣៩៩/៧២

## ស្តីពី

## ការបង្កើត ឧត្តមក្រុមប្រឹក្សា កំណែទំរង់រដ្ឋ

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពី នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ស្របតាមការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំ ថ្ងៃទី១២ ខែមីនា ឆ្នាំ ១៩៩៩

ត្រាស់បង្គាប់

### ជំពូកទី ១

### ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

មាត្រា ១ .- ត្រូវបានបង្កើត ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ដែលទទួលបន្ទុក លើកសំណើជូនរាជរដ្ឋាភិបាល នូវកំណែទំរង់សំខាន់ៗ ដែលទាក់ទងទៅនឹងបេសកកម្ម និងការប្រព្រឹត្តិទៅរបស់បណ្តាស្ថាប័នរដ្ឋ ក៏ដូចជា ខ្លឹមសារ និង បែបបទទាំងឡាយ នៃការដាក់អោយដំណើរការនយោបាយតាមផ្នែកនានា ព្រមទាំងជំរុញ តាមដាន និងសំរបសំរួល ក្នុងនាមរាជរដ្ឋាភិបាល នូវការអនុវត្តន៍ កំណែទំរង់ទាំងនោះ ។

មាត្រា ២ .- ក្នុងការប្រតិបត្តិបេសកកម្មដូចមានចែងក្នុងមាត្រា១ ខាងលើ ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋត្រូវបានជួយជាកម្លាំង ដោយក្រុមប្រឹក្សាកំណែទំរង់ មួយចំនួន ដែលទទួលបន្ទុកផ្តួចផ្តើម និងជំរុញអោយដំណើរការ នូវគំរោងកំណែទំរង់ ពាក់ព័ន្ធទៅនឹងស្ថាប័នរដ្ឋណាមួយ ឬក្នុងផ្នែកណាមួយ នៃវិស័យសេដ្ឋកិច្ចសង្គមកិច្ចរបស់ប្រទេសក្នុងនាម និងក្រោមការត្រួតពិនិត្យមើល របស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

ក្រុមប្រឹក្សាកំណែទំរង់នីមួយៗ ត្រូវបានដឹកនាំដោយប្រធានមួយរូប និង មានអគ្គលេខាធិការដ្ឋានមួយដែលទទួលបន្ទុក សំរបសំរួល និងតាមដានជាអចិន្ត្រៃយ៍ នូវកម្មវិធីកំណែទំរង់ ក្រោមអាជ្ញាធររបស់ប្រធាន ។

ក្រុមប្រឹក្សាកំណែទំរង់នីមួយៗ នឹងត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ ។

មាត្រា ៣ ._ ដើម្បីប្រតិបត្តិបេសកកម្ម ដូចមានចែងក្នុងមាត្រា ខាងលើ ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវបំពេញមុខការដូចតទៅ :

១-លើកសំណើស្តីពីការបង្កើត ឬ ការផ្លាស់ប្តូរ ក្រុមប្រឹក្សាកំណែទំរង់ ។

២-តំរង់ទិស សកម្មភាពទាំងអស់ របស់ ក្រុមប្រឹក្សាកំណែទំរង់នីមួយៗ ។ សំរបសំរួលសកម្មភាព និងត្រួតពិនិត្យមើល លទ្ធផលទាំងអស់ របស់ក្រុមប្រឹក្សានីមួយៗ ។

៣-លើកសំណើជូនរាជរដ្ឋាភិបាល នូវគំរោងអត្ថបទច្បាប់ និង បទបញ្ញាចាំបាច់ សំរាប់ដាក់អោយដំណើរការកំណែទំរង់នានា ។

៤-ចេញសេចក្តីសំរេច និង សេចក្តីណែនាំសំខាន់ៗ ដល់ការដាក់អោយដំណើរការកំណែទំរង់នានា ក្នុងព្រំដែនសមត្ថកិច្ចរបស់ខ្លួន ។

មាត្រា ៤ ._ ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឧបនាយករដ្ឋមន្ត្រីទាំងពីរ | អនុប្រធាន |
| ៣- ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកអចិន្ត្រៃយ៍ |
| ៤- ប្រធាន ក្រុមប្រឹក្សា កំណែទំរង់រដ្ឋបាល | សមាជិក |
| ៥- ប្រធានក្រុមប្រឹក្សាកំណែទំរង់កងកំលាំងប្រដាប់អាវុធ | សមាជិក |
| ៦- ប្រធានក្រុមប្រឹក្សារំសាយ កងកំលាំងប្រដាប់អាវុធ | សមាជិក |
| ៧- ប្រធានក្រុមប្រឹក្សាកំណែទំរង់ ប្រព័ន្ធយុត្តិធម៌ | សមាជិក |
| ៨- ប្រធានក្រុមប្រឹក្សាកំណែទំរង់សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ | សមាជិក |

អង្គការលេខ របស់ ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវបានកំណត់នៅក្នុង ឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ ។

មាត្រា ៥ ._ ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ កំណត់របៀបវារៈនៃការប្រជុំនានា ដឹកនាំការពិភាក្សា និងកំណត់សេចក្តីសំរេចទាំងអស់ ។

ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ អាចអញ្ជើញ គ្រប់សមាជិករាជរដ្ឋាភិបាល ឬ ឥស្សរជនដែលមានគុណសម្បត្តិគ្រប់គ្រាន់ មកចូលរួមក្នុងការប្រជុំ របស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

ការរៀបចំការប្រជុំទាំងឡាយរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ និង ការតាមដាននៃការអនុវត្តន៍នូវសេចក្តីសំរេចទាំងអស់របស់ខ្លួន ត្រូវបានរ៉ាប់រងដោយសមាជិកអចិន្ត្រៃយ៍ដោយមានបង្អែកបច្ចេកទេស របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ២

## អវសានប្បញ្ញត្តិ

មាត្រា ៦ ._ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧ ._ នាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៨ ._ ព្រះរាជក្រឹត្យនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៩ ខែ មីនា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

## ឧបសម្ព័ន្ធ

## អង្គការលេខរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

